# រឿង មហាចោរនៅទល់ដែន

## ភាគទី៦៧ (ផែនការសម្ងាត់)

ក្បួនការពារឯករាជ្យ បានមកដល់ស្រុកមណ្ឌលបុរី។ គឺនៅទីនេះហើយ ដែលព្រះនាងខត្តិយាណីកែវមណីបម្រុងនឹងសម្រេចផែនការទីពីរបស់ព្រះនាង គឺផែនការផ្តាច់ជីវិតព្រះកម្ពុតជាឪពុកមា រួមដៃជាមួយមេទ័ពកាមា និងសហជីវិនខ្វះដែលគេអាចរាប់អស់នឹងម្រាមដៃ មាននិលពេជ្រ និលឯកបក្សីជាដើម។

មួយថ្ងៃផុតទៅ ការតឹងតែងក្នុងស្រុកក៏ចេះតែរីតធំឡើងៗ គំនិតជាន់លើសរិសាពស្រ្តទាំងអស់ ដើម្បីដំឡើងខ្លួន ឲ្យខ្ពស់ផុតគេផុតឯង ធ្វើឲ្យមនុស្សដែលបិញ្ចឹមគំនិតនេះ គិតចេះតែខុស ប្រព្រឹត្តចេះតែធ្ងន់។

មើលហ៎ៗ ផែនការព្រះនាងមណីចេះតែអាក្រក់ទៅៗ ឥតត្រើយ។ ក្នុងរាត្រីនោះ កញ្ញាឯកបានប្រជុំអស់សហជីវិនដើម្បីអោយជនទាំងនេះទទួលកិច្ចបញ្ជាជាចុងក្រោយបង្អស់។

ក្នុងរាត្រីដដែលនេះ មានទូមហាចោរនៅទល់ដែន ដែលជីតាឆើតស្មានថាស្លាប់ទៅហើយនោះ កំពុងទទួលទានបាយយ៉ាងស្ងប់ស្ងៀមស្រួលបួលជាមួយតាគីរីសុមេរុក្នុងផ្ទះតៀមតូចមួយ មានទូអង្គុយនៅមាត់បង្អួចដៃកាន់ក្ញៅមាន់បរិភោគយ៉ាងឆ្ងាញ់ពិសា។

នៅពីមុខផ្ទះតៀមនេះ គេហដ្ឋានដ៏ស្កុកស្កម្ភអើតកម្ពស់ត្រដែតទៅក្នុងមេឃងងឹត។ យូរៗ មានទូបង្អើបស្បែងបង្អួចចោលកន្ទុយភ្នែកទៅលើស្វាបព្រិលមាត់ទ្វារនៃគេហដ្ឋានដ៏ស្កុកស្កម្ភនោះ ដែលបិទជិតឃើញតែពន្លឺចង្កៀងជះលឹមៗ មកខាងក្រៅ។

មានទូសួរតាសុមេរុថា:

ផ្ទះនោះជាផ្ទះអ្នកណា?

តាសុមេរុសម្លឹងមើលតាមមានទូ មាត់ទំពាសាច់មាន់បណ្តើរ តបបណ្តើរ:

ផ្ទះនោះគឺជាផ្ទះព្រះកន្ទាថន។ ពីដើមគេមានប្រាក់ច្រើន គេតែងសង់ផ្ទះត្រង់នេះ ត្រង់នោះសម្រាប់មកលំហែលេង។ រួចគ្មានអ្នកណាមួយហ៊ានចូលសំពកឬចូលលេងក្នុងផ្ទះនោះបានឡើយ។ មើលចុះតាមិនដែលឃើញមាត់ទ្វារនិងមាត់បង្អួចផ្ទះនេះបើកម្តងណាទេ គឺឃើញតែគេបិទជួច្នោះឯង។

អត្ថបទដោយៈ មាស សុភាព

មានន្ទសញ្ជឹងគិតចង់ចញ្ចើមៗ បុរសនឹកដល់វាស្រ្តអ្នកដែលអត់ផ្ទះនៅ ក្មេងៗអត់សាលារៀន ។ល។ អ្នកគ្រវីក្បាល! រួចគ្រវាត់ឆ្អឹងមាន់ព្រួសទៅលើក្តារនិយាយថា:

ទេ! ពេលនេះ មានមនុស្សចូលទៅប្រជុំនៅទីនោះឯង។ ខ្ញុំចង់ដឹងតើគេប្រជុំរឿងអ្វី?

តាសុមេរុនិយាយសំឡេងធ្ងន់ៗថា:

ហ៊ឺស! គេធ្វើអ្វី! គេមានអ្វីធ្វើ ក្រៅពីប្រជុំគ្នាដើម្បីបង្កកល្ល៍យុគអ្វីមួយនោះ ត្បិតចៅជ្រាបស្រាប់ ហើយស្ត្រីកែវមណីគេប្រជុំនោះ។

មែន! ខ្ញុំឃើញស្ត្រីនេះរំកិលខ្លួនចោលទៅក្នុងផ្ទះនោះឯង រួចកាមា រួចនិលពេជ្រ រួចនិលឯក។

តាគីរីក្រោកឈរចាក់ទឹកតែពីកែវដកដង្ហើមធំ រួចនិយាយថា:

ណ្ហើយចៅអើយ! តាមតែគេទៅ គេធ្វើអ្វីក៏ធ្វើចុះៗ តែតាបានជួបចៅពេលនេះ តាចង់និយាយលេងជាមួយចៅអោយបានយូរ តែខ្លាចចៅរវល់គំនិតពេក។ មានន្ទឈប់មើលទៅផ្ទះខាងមុខបែរមកចាប់ពែងតែផឹកក្អៀកនៅធ្មឹងឥតមើលមុខតាគីរីឡើយ! តាគីរីបម្រះខ្លួនទៅលើជើងម៉ាមួយវែងអុជខ្សៀបផ្លុយផ្សែងនិយាយថា:

ប្រហែលចៅមិនចង់ស្ដាប់តាទេ ពីព្រោះចៅមិនដឹងចិត្តតាសោះ

មានន្ទរិះរកមើល តើតាគីរៅជាទីគោរពនេះចង់និយាយអំពីអ្វី? អ្នកនឹកមមៃថា ប្រហែលតាគីរីចង់និយាយពីទេវីកាឡកិណ្ណីហើយ។ អនុស្សាវរីយ៍ចាស់ដ៏ធ្ងួលឆេះឡើងឥតស្រាកស្បើយឡើយ។ អ្នកខាំធ្មេញញ៉ីអស់បេះដូង។ បើក្រៅពីតាគីរី មានន្ទមុខជាវាយដុំមិនខាន។ តែ …នេះទោះខឹងយ៉ាងណាក៏ត្រូវគោរពគាត់ជាចាស់ទុំដែរ។

មានន្ទធ្វើជាសើចតិចៗ

ហាស់ៗ លោកតាចង់មានប្រសាសន៍ពីអីសុំឲ្យមានប្រសាសន៍មក! ធ្លាប់ស្គាល់ខ្ញុំស្រាប់!

អើ! តាសដឹងហើយថាចៅមានចិត្តខ្លាំង ចៅមានចិត្តដាច់ៗ តាសរសើរចៅណាស់ ព្រោះថាកើតមកជាកូនប្រុសត្រូវតែមានចិត្តដូច្នោះឯង…

មានន្ទញញឹមស្ងួត តែចុកណែនអស់ដើមទ្រូង មុខឡើងក្រហមតែបុរសស្ដាប់ឥតប្រកែកឡើយ ដូចតទៅ:

អត្ថបទដោយ៖ មាស សុភាព

រឿងអីលោកតា ខ្ញុំចង់ដឹងណាស់ មានប្រសាសន៍មកកុំព្រួយបារម្ភអ្វី ខ្ញុំស្តាប់ទាំងអស់ បើរឿងល្អខ្ញុំតាម រឿងអាក្រក់ខ្ញុំមិនតាម។

អឺៗ! ប្រសើរណាស់! ប្រសើរណាស់ចៅ!

តាគីរីលូករាវក្នុងហោប៉ៅហកសំបុត្រមួយមកបង្ហាញមាននូៗ មាននូស្មុះភ្លែតទៅជិតតាគីរីប្រាថ្នាហកសំបុត្រនោះមកមើលភ្លាមៗ តែតាគីរីរាដៃ:

កុំអាលៗ ជារឿងសំខាន់ណាស់!

សំខាន់យ៉ាងណាខ្ញុំចង់ដឹង?

គង់តែចៅបានដឹងទេ

និយាយពីអ្វី?

គង់តែចៅបានដឹងទេ! តែមុននឹងយកសំបុត្រនេះ សូមសច្ចាអោយតាសិន!

សច្ចាយ៉ាងណា?

សច្ចាថា មើលសំបុត្រនេះចប់ចុងចប់ដើម មានអារក្ខទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម អារក្សអ្នកតាបិសាច បង់បត់ជាសាក្សី។

ខ្ញុំសច្ចា! សច្ចាយ៉ាងណាទៀត?

សច្ចាថា មើលសំបុត្រនេះរួចឲ្យពិចារណា!

បាទ!

អើ! មើលចុះៗ

**(សូមរង់ចាំតាមដានភាគទី៦៨ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព